# អនុស្សរណៈនៃការយោគយល់គ្នា

# ស្តីពី

# សហប្រតិបត្តិការសេដ្ឋកិច្ច និង ពាណិជ្ជកម្ម

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# និង

# សាធារណរដ្ឋ អ៊ូហ្គង់ដា

តាមការអញ្ជើញរបស់ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា គណៈប្រតិភូមួយរបស់ ក្រសួងទេសចរណ៍ ពាណិជ្ជកម្ម និង ឧស្សាហកម្ម នៃសាធារណរដ្ឋ អ៊ូហ្គង់ដា ដឹកនាំដោយឯកឧត្តម បណ្ឌិត **Abel Rwendeire** ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានមកបំពេញទស្សនកិច្ចសិក្សាមួយនៅ ព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២៣ ដល់ ២៧ ខែ មិថុនា ឆ្នាំ ២០០២ ។

ក្នុងអំឡុងពេលនៃការស្នាក់នៅ ឯកឧត្តមទេសរដ្ឋមន្ត្រី បានធ្វើការពិភាក្សាយ៉ាងទូលំទូលាយជាមួយ ឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង មន្ត្រីជាន់ខ្ពស់ជាច្រើន នៃក្រសួងពាណិជ្ជកម្ម អំពី វិធីសាស្ត្រ និង មធ្យោបាយដើម្បីអភិវឌ្ឍន៍ចំណងទាក់ទងផ្នែកពាណិជ្ជកម្ម និង សហប្រតិបត្តិការសេដ្ឋកិច្ច រវាងកម្ពុជា និង អ៊ូហ្គង់ដា ។ ភាគីទាំងពីរបានផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមកលើការធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និង បង្កើតនូវបរិស្ថានល្អប្រសើរ ដើម្បីទាក់ទាញការធ្វើវិនិយោគដោយផ្ទាល់របស់បរទេស ដោយផ្អែកលើភាពវាងវៃ និង ការដឹកនាំប្រកបដោយប្រត្យក្សភាពនៃថ្នាក់ដឹកនាំរបស់ប្រទេសទាំងពីរ ដែលបានផ្តល់លទ្ធភាពអោយ ។ បទពិសោធន៍របស់ប្រទេសកម្ពុជា ក្នុងនាមជាប្រទេសគំរូមួយក្នុងការអនុវត្តក្របខ័ណ្ឌសមាហរណកម្មជំនួយបច្ចេកទេស ទាក់ទងនឹងវិស័យពាណិជ្ជកម្ម ដែលផ្តល់អោយបណ្តាប្រទេសអភិវឌ្ឍន៍យឺត (LDCs) សំដៅជំរុញចរន្តពាណិជ្ជកម្ម ទៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ក៏ដូចជាក្នុងនាមជាប្រទេសគំរូឈានមុខមួយក្នុងការផ្សារភ្ជាប់ពាណិជ្ជកម្មទៅ នឹងបទដ្ឋានពលកម្មក្នុងវិស័យឧស្សាហកម្មវាយនភ័ណ្ឌ និង សំលៀកបំពាក់ បានរួមចំណែកផងដែរ ក្នុងការផ្តល់បទពិសោធន៍ដល់ គណៈប្រតិភូ អ៊ូហ្គង់ដា ។



Rh

CB

គណៈប្រតិភូក៏បានជួបប្រជុំជាមួយ ឯកឧត្តម **ចន្ទ័ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីសក្តានុពលកសិកម្មរបស់កម្ពុជា ដូចជា វិស័យផលិតកម្ម និង ការនាំចេញ ផលនេសាទ ស្រូវ អង្ករ និង កប្បាស ។

គណៈប្រតិភូក៏បានជួបពិភាក្សាផងដែរ ជាមួយសមាជិករបស់ផ្នែកឯកជនជាពិសេសវិស័យឧស្សាហកម្ម វាយនភ័ណ្ឌ និង សំលៀកបំពាក់ ។

ដោយគិតគូរដល់ភាពប្រហាក់ប្រហែលគ្នានៃបរិបទសង្គមសេដ្ឋកិច្ច នៃប្រទេសទាំងពីរ ហើយដោយមានបំណងចង់ជំរុញអោយមានទំនាក់ទំនងសេដ្ឋកិច្ច និង ពាណិជ្ជកម្មកើនឡើងថែមទៀត រវាងប្រទេសខាងត្បូង និង ប្រទេសខាងត្បូង នៃប្រទេសទាំងពីរ ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ :

១- ជំរុញអោយមានចំណងទាក់ទងរវាងប្រទេសទាំងពីរ និង ក្រសួងពាក់ព័ន្ធនៃប្រទេសទាំងពីរ លើវិស័យពាណិជ្ជកម្ម និង សេដ្ឋកិច្ច ។

២- ផ្លាស់ប្តូរពត៌មានទៅវិញទៅមក ស្តីពីវិស័យពាណិជ្ជកម្ម និង អាជីវកម្មរបស់ប្រទេសទាំងពីរ

៣- ផ្លាស់ប្តូរបេសកកម្ម និង ទស្សនកិច្ចសិក្សាលើវិស័យពាណិជ្ជកម្ម និង វិនិយោគ ។

៤- ផ្លាស់ប្តូរបទពិសោធន៍ថែមទៀតក្នុងការអនុវត្តក្របខ័ណ្ឌសមាហរណកម្មជំនួយបច្ចេកទេស (IF)ដើម្បីអភិវឌ្ឍន៍យុទ្ធសាស្ត្រពាណិជ្ជកម្មនៃការកាត់បន្ថយភាពក្រីក្រនៃប្រទេសទាំងពីរ ។

៥- ជំរុញអោយមានសហប្រតិបត្តិការ និង ការពិគ្រោះយោបល់កាន់តែជិតស្និទ្ធឡើងក្នុងចំណោមប្រទេសអភិវឌ្ឍន៍យឺត ទាក់ទងដល់ បញ្ហានៅក្នុងតំណាក់កាលក្រោយការចរចាពាណិជ្ជកម្មនៅទីក្រុងដូហា ។

៦- ស្វះស្វែងរកលទ្ធភាពដើម្បីបង្កើតស្ថានកុងស៊ុលកិត្តិយសនៅក្នុងប្រទេសទាំងពីរ ។

៧- ប្រកាន់យកសកម្មភាពសហប្រតិបត្តិការដទៃទៀតរួមទាំងជំនួយបច្ចេកទេសផង ដូចដែលបានកំណត់ដោយក្រសួងនៃប្រទេសទាំងពីរ ។

៨- រួមកំលាំងគ្នាក្នុងការជំរុញ និង សំរួលការចូលជាសមាជិករបស់កម្ពុជា ទៅក្នុងអង្គការពាណិជ្ជកម្មពិភពលោក ប្រកបដោយ លក្ខខ័ណ្ឌដែលសមស្របទៅនឹងកំរិតអភិវឌ្ឍន៍របស់កម្ពុជា ។

៩- ចែករំលែកបទពិសោធន៍របស់ប្រទេសអ៊ូហ្កង់ដា នៅក្នុងការកែច្នៃ និង នាំចេញផលិតផលនេសាទទៅកាន់ទីផ្សារសហគមន៍អឺរ៉ុប ។



Ph CB

១០-ជំរុញអោយមានគំនិតផ្តួចផ្តើមសម្ពន្ធ័ភាព-អាស៊ី-អាហ្វ្រិក ដោយអំពាវនាវអោយមានការផ្តល់លក្ខខ័ណ្ឌអនុគ្រោះ GSP ដល់គ្នាទៅវិញទៅមកក្នុងចំណោមប្រទេសអភិវឌ្ឍន៍យឺត ។

គណៈប្រតិភូអ៊ូហ្គង់ដា បានសម្តែងនូវបំណងស្នើសុំអញ្ជើញឯកឧត្តម **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ទៅធ្វើទស្សនកិច្ចតបស្នងវិញនៅសាធារណរដ្ឋ អ៊ូហ្គង់ដា នាពេលអនាគត ។

ដើម្បីជាសក្ខីកម្ម ភាគីទាំងពីរ បានចុះហត្ថលេខាលើអនុស្សារណៈនៃការឯកភាពយល់នេះ ។

អនុស្សារណៈនេះធ្វើឡើងជា ០២ ច្បាប់ ជាភាសាខ្មែរ និង ភាសាអង់គ្លេស នៅភ្នំពេញ នាថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០២ ។

**ចម ប្រសិទ្ធ**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**ព្រះរាជាណាចក្រកម្ពុជា**

**អេបែល រ៉ែនដៀរ**
**ទេសរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**សាធារណរដ្ឋ អ៊ូហ្គង់ដា**